<u>សូមគោរពជូន</u>

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី  រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច  និងហិរញ្ញវត្ថុ

ឯកឧត្តមរដ្ឋមន្ត្រី  ក្រសួងកសិកម្ម  រុក្ខាប្រមាញ់  និងនេសាទ

ឯកឧត្តមរដ្ឋមន្ត្រី  ក្រសួងឧស្សាហកម្ម  រ៉ែ  និងថាមពល

ឯកឧត្តមរដ្ឋមន្ត្រី  ក្រសួងសាធារណការ  និងដឹកជញ្ជូន

ឯកឧត្តមរដ្ឋមន្ត្រី  ក្រសួងទេសចរណ៍

លោកជំទាវ រដ្ឋមន្ត្រី  ក្រសួងកិច្ចការនារី

ឯកឧត្តមរដ្ឋមន្ត្រី  ក្រសួងវប្បធម៌  និងវិចិត្រសិល្បៈ

ឯកឧត្តមអគ្គលេខាធិការ  នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ឯកឧត្តម  ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ  និងរដ្ឋាករកម្ពុជា

ឯកឧត្តម  នាយកសាលាភូមិន្ទរដ្ឋបាល

<u>កម្មវត្ថុ:</u> សំណើសុំអញ្ជើញ ឯកឧត្តម លោកជំទាវ ជាសមាជិកនៃគណៈកម្មការ (Implementation Committee) និងក្រុមការងារសម្រាប់អនុវត្តន៍ មូលនិធិពហុភាគី និងសម្របសម្រួលអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ចូលរួមកិច្ចប្រជុំលើកទី ១០ នៅក្រសួងពាណិជ្ជកម្ម ។

<u>ជូនភ្ជាប់:</u> របៀបវារៈនៃកិច្ចប្រជុំ និងឯកសារពិភាក្សា។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ដើម្បីជំរុញការអនុវត្ត Trade SWAp ឱ្យមានសន្ទុះតាមការគ្រោងទុក ក្រសួងពាណិជ្ជកម្មសូមអញ្ជើញសមាជិកនៃគណៈកម្មការ និងក្រុមការងារសម្រាប់អនុវត្តន៍មូលនិធិពហុភាគី និងសម្របសម្រួលអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) <u>**ចូលរួមប្រជុំពិនិត្យ និងវាយតម្លៃសម្រេចលើគម្រោងយុទ្ធសាស្ត្រចំនួនបីកញ្ចប់ដែលស្ថិតនៅក្នុងរបាយការណ៍នៃ Mid Term Review ដើម្បីសម្រេចបានតាមការកំណត់ឱ្យគម្រោង TDSP អនុម័តសម្រេចបានយ៉ាងហោចណាស់ចំនួនបីនៅដំណាច់ ខែមិថុនា នេះ រួចស្នើមកសុំការគាំទ្រផ្នែកហិរញ្ញវត្ថុមុន នឹងដាក់**</u>

**ជូនអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងទៅនឹងពាណិជ្ជកម្ម** (SSC.TD-TRI ) **ដើម្បីសម្រេចនិងអនុវត្តន៍** ។

កិច្ចប្រជុំនេះនិងប្រព្រឹត្តទៅនៅ**ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ វេលាម៉ោង ០៨:៣០ នាទីព្រឹក នៅសាលប្រជុំនៃក្រសួងពាណិជ្ជកម្ម អាគារលេខ ១៩-៦១ ផ្លូវ ១១៣ សង្កាត់ទឹកល្អក់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ** ក្រោមអធិបតីភាពឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការអនុវត្តន៍។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** មេត្តាចាត់បញ្ជូនឯកឧត្តម លោកជំទាវ ជាសមាជិកនៃគណៈកម្មការ និងក្រុមការងារសម្រាប់អនុវត្តន៍មូលនិធិពហុភាគី និងសម្របសម្រួលអភិក្រមគ្រប់ដណ្តប់លើវិស័យពាណិជ្ជកម្មចូលរួមប្រជុំតាមកាលកំណត់ខាងលើដោយអនុគ្រោះ ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

***ចម្លងជូន :***

- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកឧត្តម ប៉ាន សូរស័ក្តិ
- ឯកឧត្តម សុខ សុភ័ក្រ្ត
- ឯកសារ-កាលប្បវត្តិ

***ទំនាក់ទំនងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ :***

ទូរស័ព្ទ : ០១៧ ៩៧៧ ៦៩៦

: ០៩២ ៨០៨ ២៦៨

អ៊ីមែល : seng.ramy@gmail.com
mollyhean7@yahoo.com